អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

**សកម្មភាព** ៖ **ល្បែងប្រើមាត់គូររូប**

**សិក្សាសង្គម៖ (គំនូរ និងសកម្មភាពកសាង)៖** ការយល់ដឹង និងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព

**គោលបំណង** ៖

**សិក្សាសង្គម** ៖ រោយ ដេរ ត្បាញ គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់ដើម្បីបង្កើតជារូបភាពផ្សេងៗ និងបង្ហាញពីអ្វីដែលគេបានបង្កើត។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសស និងខ្មៅដៃពណ៌

**កម្រិតសិក្សា** ៖ ទាប មធ្យម និងខ្ពស់

**ការរៀបចំ** ៖ ត្រៀមខ្មៅដៃ និងខ្មៅដៃពណ៌ឱ្យបានរួចរាល់ និងសម្អាតវាឱ្យបានស្អាតដែរ និងក្រដាសសឱ្យបានគ្រប់គ្រាន់។

**សេចក្តីណែនាំ៖**

(ល្បែងនេះលេងក្រោយពីក្មេងៗស្តាប់រឿងនិទានរួច «យើងអាច គ្រាន់តែតាមវិធីផ្សេងគ្នា»ក៏បាន។)

1. ប្រាប់ពួកគេថា ថ្ងៃនេះយើងទាំងអស់គ្នានឹងព្យាយាមគូររូបដោយរបៀបដូចជា ទីដែរ។
2. ចាប់ផ្តើមចែកក្រដាសស ខ្មៅដៃ និងខ្មៅដៃពណ៌មួយចំនួនសម្រាប់ក្មេងៗឱ្យបានគ្រប់គ្រាន់។
3. ប្រាប់ក្មេងៗឱ្យចាប់ផ្តើមជាមួយការគូររូបភាពដោយប្រើមាត់ និងផាត់ពណ៌ដោយមាត់ដូចគ្នា។
4. នៅពេលដែលលេងល្បែងចប់ ប្រាប់ឱ្យក្មេងៗរៀបចំ និងសម្អាតសម្ភារឱ្យបានស្អាតជាការស្រេច។